# និយមន័យនៃការតស៊ូមតិ

## Definition of Advocacy

សូមគូសរូបម្នាក់មួយលើ
ក្រដាស់សនិងក្រដាស់ពណ៌
ពន្យល់ពាក្យថាតស៊ូមតិមាន
ន័យដូចម្តេចសម្រាប់អ្នក!

# វិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ
# API / Pact Cambodia

គឺជាកម្រងសកម្មភាពជាយុទ្ធសាស្រ្ត ដែលរៀបចំឡើង ដើម្បីដាក់ឥទ្ធិពលទៅលើអ្នកកាន់កាប់អំណាចរដ្ឋាភិបាល នយោបាយ សេដ្ឋកិច្ច ឬ ឯកជន ដើម្បីឱ្យពួកគេអនុវត្តគោលនយោបាយសាធារណៈ និង ការប្រតិបត្តិនានា ដែលផ្តល់ផលប្រយោជន៍ដល់អ្នកមានអំណាចនយោបាយតិច និង ធនធានសេដ្ឋកិច្ចតិច (ក្រុមដែលទទួលផលប៉ះពាល់) ។

# ពាក្យគន្លឹះ

-កម្រងសកម្មភាព ជាយុទ្ធសាស្ត្រ

-ដាក់ឥទ្ធិពលលើអ្នកមានអំណាច

-អនុវត្តគោលនយោបាយសាធារណៈ ឬការប្រតិបត្តិនានា

-ផ្តល់ផលប្រយោជន៏ដល់អ្នកមានអំណាចតិច ។

# និយមន័យការតស៊ូមតិថ្នាក់មូលដ្ឋាន៖
# (API, PACT, LWF, ADHOC)

ការតស៊ូមតិថ្នាក់មូលដ្ឋាន គឺជាសកម្មភាពដែលធ្វើឡើង ដើម្បីទាមទារឱ្យមានដំណោះស្រាយបញ្ហាប៉ះពាល់រួម តាមរយៈការធ្វើឱ្យមានឥទ្ធិពលទៅលើអ្នកមានអំណាចផ្លាស់ប្តូរ ។

# អ្នកតស៊ូមតិមានតួនាទីសំខាន់ៗ៖

- សិក្សាករណី ឬផលប៉ះពាល់ឱ្យបានច្បាស់លាស់
- ផ្តល់ព័ត៌មានចាំបាច់ដល់អ្នកភូមិ ឬសហគមន៏ (សមាជិកក្រុម) រួមទាំងព័ត៌មានពីអ្នកធ្វើសេចក្តីសម្រេច និង អ្នកពាក់ព័ន្ធ
- ប្រមូលភ័ស្តុតាង និង អង្គហេតុនៃបញ្ហា
- កសាងបណ្តាញប្រជាពលរដ្ឋ ឬសហគមន៏ ទាំងក្នុង និងក្រៅ
- កៀរគរធនធានទាំងក្នុង និងក្រៅភូមិ ឬសហគមន៏
- ពិគ្រោះយោបល់អំពីច្បាប់ ឬបទប្បញ្ញត្តិពាក់ព័ន្ធ របៀបចរចា វិធីសាស្ត្រអហិង្សាសកម្មនិងសកម្មភាពដើម្បីដាក់ការកៀបសង្កត់ផ្សេងៗដល់អ្នកបង្កបញ្ហា និងអ្នកធ្វើសេចក្តីសម្រេច
- ធ្វើសកម្មភាពដឹកនាំយុទ្ធនាការតស៊ូមតិដោយផ្ទាល់ខ្លួន។

| តួនាទី | និយមន័យ | គំនូសបំព្រួញ |
|---|---|---|
| ធ្វើជាតំណាង | បញ្ចេញមតិក្នុងនាមប្រជាពលរដ្ឋ |  |
| ហែហម ឬ រួមដំណើរ | ចូលរួមបញ្ចេញមតិជាមួយប្រជាពលរដ្ឋ |  |
| ពង្រឹងសិទ្ធិអំណាច | ផ្តល់លទ្ធភាពឱ្យប្រជាពលរដ្ឋបញ្ចេញមតិ ឬ សន្ទនាដោយខ្លួនឯង |  |
| ជាអ្នកសម្រុះសម្រួល ឬ អ្នកកណ្តាល | ជួយសម្របសម្រួលការប្រាស្រ័យទាក់ទងរបស់ប្រជាពលរដ្ឋជាមួយក្រុមមនុស្សផ្សេងៗ |  |
| ធ្វើជាគំរូ | ធ្វើការអនុវត្តបង្ហាញគំរូដល់ប្រជាពលរដ្ឋ ឬ អ្នកធ្វើគោលនយោបាយផ្សេងៗ |  |
| ចរចា | តថ្លៃ ដើម្បីសម្រេចបំណងតស៊ូមតិ |  |
| ចងបណ្តាញ | បង្កើតសម្ព័ន្ធភាព ឬកសាងក្រុមចម្រុះ |  |

ចំណាំ:  = អ្នកតស៊ូមតិ  = អង្គគោលដៅ ឬអ្នកមានឥទ្ធិពល  = អ្នកទទួលរងនូវផលប៉ះពាល់

# ប្រភពអំណាចរបស់អ្នកតស៊ូមតិ

**១- ប្រភពអំណាចសំខាន់ៗគឺៈ**

- ការចូលរួមសាមគ្គី ( ស្រុះគ្នា)
- ការទទួលស្គាល់ពីអ្នកពាក់ព័ន្ធ ជាពិសេសអ្នកដែលរងផលប៉ះពាល់ពីបញ្ហា
- មានអ្នកតំណាង ( អ្នកដឹកនាំ) ច្បាស់លាស់ និងមានសមត្ថភាព
- ការទទួលខុសត្រូវ
- អហិង្សាសកម្ម ។

## ២- ប្រភពអំណាចផ្សេងៗទៀតគឺ ៖

- ព័ត៌មានច្បាស់លាស់អំពីបញ្ហាបានកើតឡើង
- មានទំនាក់ទំនងជាមួយមនុស្សដែលស្គាល់អ្នកមានអំណាចផ្លាស់ប្តូរ
- មានទំនាក់ទំនងល្អជាមួយបណ្តាញក្នុង និងក្រៅ
- ស្របច្បាប់ជាតិ និងអន្តរជាតិ និងតស៊ូមតិដើម្បីប្រយោជន៍រួម ។

You're looking for it!







MISS







UNITED NATIONS
mbodia Office of the High
missioner for Human Rights
NATIONS UNIES
Bureau du Haut Commissaire aux
droits de l'homme au Cambodge
កម្រងឯកសារច្បាប់
មួយចំនួនដែលកំពុងអនុវត្តនៅក្នុង
ព្រះរាជាណាចក្រកម្ពុជា
រដ្ឋសភា


អនុក្រឹត្យ
ស្តីពី
ការធ្វើវិមជ្ឈការអំណាច តួនាទី និង
ភារកិច្ច ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់










ព័ត៌មានសាធារណៈ: